

# The Return to Work scheme and work injury support គម្រោងការវិលត្រឡប់ទៅធ្វើការវិញ និងការផ្គត់ផ្គង់របួសការងារ

ReturnToWorkSA ផ្តល់នូវការធានារ៉ាប់រងដែលការពារអាជីវកម្មរដ្ឋអូស្រ្តាលីខាងត្បូង និងអ្នកធ្វើការរបស់ក្នុងព្រឹត្តិការណ៍នៃការរងរបួសការងារណាមួយ។

គម្រោងការវិលត្រឡប់ទៅធ្វើការវិញ ទទួលស្គាល់ថាបុគ្គលដែលរងរបួសយ៉ាងធ្ងន់ធ្ងរ ត្រូវការការផ្គត់ផ្គង់ខុសៗគ្នាពីបុគ្គលដែលមិនរងរបួស។

### ការផ្គត់ផ្គង់សម្រាប់បុគ្គលដែលរងរបួស អាចបញ្ចូលទាំង:

- ប្រាក់ចំណូលផ្គត់ផ្គង់ដើម្បីជាសំណងទូទាត់ចំពោះការបាត់បង់នៃប្រាក់បៀវត្សរ៍ សម្រាប់អំឡុងពេលរហូតដល់ទៅពីរឆ្នាំ - ជាទូទៅចាប់ផ្តើមពីថ្ងៃនៃការរងរបួស
- ការព្យាបាលផ្នែកពេទ្យដែលសមហេតុផល និងចាំបាច់ ហើយនិងការថែទាំរហូតដល់ទៅបីឆ្នាំ ចាប់ពីថ្ងៃនៃការរងរបួសរបស់គេ
- សេវាផ្គត់ផ្គង់ការវិលត្រឡប់ទៅធ្វើការវិញ ដូចជាការរកការងារឲ្យធ្វើ និងការហ្វឹកហ្វឺនឡើងវិញ រហូតដល់ទៅបីឆ្នាំ ចាប់ពីថ្ងៃនៃការរងរបួសរបស់គេ។

### ការផ្គត់ផ្គង់សម្រាប់មនុស្សដែលរងរបួសយ៉ាងធ្ងន់ធ្ងរ អាចរួមបញ្ចូលទាំង:

- ប្រាក់ចំណូលផ្គត់ផ្គង់ រហូតដល់អាយុចូលនិវត្តន៍
- ការព្យាបាលផ្នែកពេទ្យដែលសមហេតុផល និងចាំបាច់ ហើយនិងការថែទាំអស់មួយជីវិត
- សេវាផ្គត់ផ្គង់ការវិលត្រឡប់ទៅធ្វើការវិញ ប្រសិនបើមានការស្នើសុំ។

នៅក្នុងព្រឹត្តិការណ៍នៃការរងរបួសការងារណាមួយ ដែលលោកអ្នកទំនងជាមិនអាចធ្វើការអស់រយៈពេលច្រើនជាងពីរសប្តាហ៍ ភ្នាក់ងារទាមទាររបស់លោកអ្នកនឹងព្យាយាមដើម្បីបញ្ជូនអ្នកគ្រប់គ្រងករណីម្នាក់ ទៅកាន់កន្លែងធ្វើការរបស់លោកអ្នក ដើម្បីជួបលោកអ្នក និងនិយោជករបស់លោកអ្នក ហើយតភ្ជាប់លោកអ្នកទៅនឹងសេវាព្យាបាល ការថែទាំ និងការផ្គត់ផ្គង់នានាដែលតម្រូវក្នុងគោលបំណងជួយលោកអ្នកឲ្យអាចវិលត្រឡប់ទៅធ្វើការវិញឲ្យបានឆាប់តាមលទ្ធភាពធ្វើទៅបាន។ ការមកជួបផ្ទាល់នឹងមុខនៅកន្លែងធ្វើការនឹងកើតមានឡើងយ៉ាងឆាប់ តាមលទ្ធភាពអាចធ្វើទៅបាន បន្ទាប់ពីបានទទួលដំណឹងអំពីការរងរបួសណាមួយ។

# What to do if you are injured អ្វីដែលត្រូវធ្វើប្រសិនបើលោកអ្នករងរបួស

ប្រសិនបើលោកអ្នកបានរងរបួសនៅកន្លែងធ្វើការ មានជំហានសំខាន់ៗមួយចំនួនដែលលោកអ្នកត្រូវចាត់វិធានការ។

## ជំហាន១៖ ស្វែងរកការព្យាបាលដែលសមស្រប។

## ជំហាន២៖ ជូនដំណឹងទៅនិយោជករបស់លោកអ្នក

លោកអ្នកត្រូវតែជូនដំណឹងទៅនិយោជករបស់លោកអ្នក ទោះដោយការសរសេរ ឬដោយពាក្យសម្ដីក្ដី ប្រសិនបើអាចធ្វើបានក្នុងរយៈពេល២៤ម៉ោងនៃការកើតមានរងរបួសរបស់លោកអ្នក។ អ្នកតំណាងណាម្នាក់ដូចជាសមាជិកគ្រួសារ ឬមិត្តភក្តិ អាចជូនដំណឹងទៅនិយោជករបស់លោកអ្នកបានដែរ ប្រសិនបើលោកអ្នកពុំអាចធ្វើដោយខ្លួនលោកអ្នកបានទេ។

## ជំហាន៣៖ ទៅជួបវេជ្ជបណ្ឌិត

វេជ្ជបណ្ឌិតនឹងវាយតម្លៃការរងរបួសរបស់លោកអ្នក ដើម្បីសម្រេចថាតើលោកអ្នកបានទទួលរងរបួសអ្វីខ្លះ ប្រភេទនៃការព្យាបាលដែលលោកអ្នកត្រូវការ មានរួមទាំងភាពញឹកញាប់ និងរយៈពេលនៃការព្យាបាល។ វេជ្ជបណ្ឌិតនឹងផ្ដល់ជូនលោកអ្នកនូវសញ្ញាបត្រសមត្ថភាពការងារមួយ ដែលលោកអ្នកនឹងត្រូវការយកវាទៅប្រគល់ជូនភ្នាក់ងារទាមទាររបស់និយោជកលោកអ្នក ជាមួយហ្វ៍មទាមទារមួយ ប្រសិនបើលោកអ្នកត្រូវការពេលឈប់ពីការងារ ហើយសម្រេចចិត្តដើម្បីធ្វើការទាមទារ។

## ជំហាន៤៖ ធ្វើការទាមទារ

ប្រសិនបើការរងរបួសរបស់លោកអ្នកបណ្ដាលឲ្យមានការឈប់ពីការងារ ឬនាំមកនូវការចំណាយផ្នែកពេទ្យ ឬការចំណាយឯទៀត ហើយលោកអ្នកចង់ធ្វើការទាមទារសម្រាប់សំណង លោកអ្នកគួរបំពេញហ្វ៍មទាមទារនោះ។

កន្លែងណាអាចធ្វើទៅបាន លោកអ្នកគួរតែបំពេញហ្វ៍មទាមទារជាមួយនិយោជករបស់លោកអ្នក។ ការនេះផ្ដល់នូវឱកាស មួយដើម្បីពិភាក្សាអំពីការផ្ដត់ផ្គង់ដែលនិយោជកអាចផ្ដល់ជូនលោកអ្នក ដើម្បីជួយលោកអ្នករក្សានៅកន្លែងធ្វើការ ឬវិលត្រឡប់ទៅធ្វើការវិញបានយ៉ាងឆាប់តាមអាចធ្វើទៅបាន ប្រសិនបើរបួសរបស់លោកអ្នកអនុញ្ញាតឲ្យលោកអ្នកធ្វើការនេះបាន។ ការនេះក៏នឹងផ្ដល់នូវព័ត៌មានត្រឹមត្រូវ និងទូលំទូលាយផងដែរ ដែលនឹងជួយជាមួយនឹងការដោះស្រាយលើការទាមទារនោះ។ ពេលណាដែលនិយោជក និងអ្នកធ្វើការពុំអាចបំពេញហ្វ៍មជាមួយគ្នាបានទេ លោកអ្នកអាចបំពេញហ្វ៍មបានដោយឡែកពីគ្នា។

ហ្វ៍មទាមទារនឹងអនុញ្ញាតឲ្យលោកអ្នកបញ្ជាក់ប្រាប់ ថាតើការទាមទាររបស់លោកអ្នកគឺសម្រាប់ការចំណាយផ្នែកពេទ្យ ការបាត់បង់ប្រាក់បៀវត្សរ៍ ឬទាំងពីរនេះ។

និយោជករបស់លោកអ្នកត្រូវបានតម្រូវឲ្យបញ្ជូនច្បាប់ចម្លងនៃហ្វ៍មទាមទារ និងច្បាប់ចម្លងនៃសញ្ញាបត្រសមត្ថភាពការងាររបស់លោកអ្នក ដែលលោកអ្នកនឹងទទួលបានពីវេជ្ជបណ្ឌិតព្យាបាលរបស់លោកអ្នក ទៅឲ្យភ្នាក់ងារទាមទាររបស់និយោជកលោកអ្នក ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពីលោកអ្នក។

កាលណាភ្នាក់ងារទាមទារបានដឹងអំពីការរងរបួសរបស់លោកអ្នកកាន់តែឆាប់ នោះគេក៏នឹងអាចរៀបចំដើម្បីតភ្ជាប់លោកអ្នក ជាមួយនឹងការព្យាបាល ការថែទាំ និងការផ្គត់ផ្គង់កាន់តែរហ័សដែរ ដើម្បីជួយលោកអ្នកឲ្យអាចជាឡើងវិញ និងវិលត្រឡប់ទៅធ្វើការវិញបានឆាប់ តាមអាចធ្វើទៅបាន។ ដើម្បីទាមទារ លោកអ្នក ឬក៏និយោជករបស់លោកអ្នកអាចទាក់ទងជាមួយភ្នាក់ងារទាមទាររបស់និយោជក:

**Gallagher Bassett Services Pty Ltd**
**GPO Box 1772, Adelaide SA 5001**
**newclaims@gb.rtwsa.com**
**Fax (08) 8177 8451**
**www.gallagherbassett.com.au**
**Phone (08) 8177 8450 or free call 1800 664 079**

**Employers Mutual SA**
**GPO Box 2575, Adelaide SA 5001**
**newclaims@employersmutualsa.com.au**
**Fax (08) 8127 1200**
**www.employersmutual.com.au**
**Phone (08) 8127 1100 or 1300 365 105**

អង្គការវិស័យឯកជន និងសាធារណៈដែលធំជាងគេបំផុតរបស់រដ្ឋអូស្ត្រាលីខាងត្បូងភាគច្រើន គឺធានារ៉ាប់រងដោយខ្លួនឯង មានន័យថាគេគ្រប់គ្រងការទាមទារសំណងរបស់អ្នកធ្វើការដោយខ្លួនគេផ្ទាល់។ ប្រសិនបើលោកអ្នកធ្វើការឲ្យអាជីវកម្មណា មួយដែលធានារ៉ាប់រងដោយខ្លួនឯង ហើយមានរបួសនៅកន្លែងធ្វើការ លោកអ្នកគួរតែនិយាយទៅកាន់និយោជករបស់លោកអ្នក ហើយរៀបចំការទាមទារសំណង។

## Your obligations កាតព្វកិច្ចរបស់លោកអ្នក

ដើម្បីសម្រេចបាននូវលទ្ធផលជាឡើងវិញ និងការវិលត្រឡប់ទៅធ្វើការវិញដ៏ល្អបំផុត យើងខ្ញុំរំពឹងទុកថាលោកអ្នក:

- ជូនដំណឹងទៅនិយោជករបស់លោកអ្នក អំពីការរងរបួសការងាររបស់លោកអ្នក ឲ្យបានឆាប់តាមអាចធ្វើទៅបាន (ក្នុងរយៈពេល២៤ម៉ោង ប្រសិនបើលោកអ្នកអាចធ្វើទៅបាន)
- ធ្វើការទាមទារឲ្យបានឆាប់ តាមដែលអាចធ្វើទៅបាន
- ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនានាដែលបានគ្រោងទុក ដើម្បីផ្តត់ផ្តង់ដល់ការជាឡើងវិញ និងការវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នក
- ចូលរួម និងសហការក្នុងការបង្កើតគម្រោងការវិលត្រឡប់ទៅធ្វើការវិញ
- អនុលោមតាមកាតព្វកិច្ចណាមួយ ដែលមានចែងនៅក្នុងគម្រោងការវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នក
- ផ្តល់សំបុត្រពេទ្យបច្ចុប្បន្នដែលបញ្ជាក់ពីសមត្ថភាពរបស់លោកអ្នកសម្រាប់ការងារ និងព័ត៌មានដែលពាក់ព័ន្ធឯទៀត
- វិលត្រឡប់ទៅកាន់ការងារដែលសមរម្យ ពេលណាអាចធ្វើទៅបាន។

## Your employer’s obligations កាតព្វកិច្ចរបស់និយោជកលោកអ្នក

យើងខ្ញុំរំពឹងទុកថា និយោជករបស់លោកអ្នកនឹងជួយផ្តត់ផ្តង់ដល់ការជាឡើងវិញ និងការវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នក ដោយ:

- ជូនដំណឹងទៅភ្នាក់ងារទាមទារអំពីការរងរបួសការងារ ឬការទាមទាររបស់លោកអ្នកក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលដំណឹងអំពីការរងរបួស ឬការទាមទារអំពីការរងរបួសការងាររបស់លោកអ្នក
- ជួយគាំទ្រដល់ការចូលរួមរបស់លោកអ្នកក្នុងការជាឡើងវិញ និងការវិលត្រឡប់ទៅសកម្មភាពការងារវិញ
- ចូលរួម និងសហការក្នុងការបង្កើតគម្រោងការវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នក
- អនុវត្តតាមកាតព្វកិច្ចណាមួយដែលមានចែងនៅក្នុង គម្រោងការវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នក
- ផ្តល់ជូនកិច្ចការសមរម្យដែលលោកអ្នកអាចអនុវត្តបានដោយសុវត្ថិភាព ក្នុងកាលលោកអ្នកបានជាឡើងវិញពីរបួសរបស់លោកអ្នក
- ផ្តល់ជូនការងារសមរម្យពេលណាលោកអ្នកមានសមត្ថភាពនឹងវិលត្រឡប់ទៅធ្វើការវិញ ប្រសិនបើលោកអ្នកមិនអាចវិលត្រឡប់ទៅកាន់ការងារមុនការរងរបួសរបស់លោកអ្នកទេ។

## Your support team ក្រុមផ្តត់ផ្តង់របស់លោកអ្នក

មនុស្សទាំងឡាយដូចតទៅនេះ ប្រហែលជាត្រូវចូលរួមក្នុងការជួយលោកអ្នកដើម្បីឲ្យបានជាពីរបួសរបស់លោកអ្នក ហើយវិលត្រឡប់ទៅធ្វើការ និងចូលរួមក្នុងសហគមន៍វិញ:

### អ្នកគ្រប់គ្រងករណី

អ្នកគ្រប់គ្រងករណីរបស់លោកអ្នក គឺជាអ្នកទំនាក់ទំនងចម្បងរបស់លោកអ្នក ហើយនឹងសម្របសម្រួលការផ្តត់ផ្តង់ និងសេវាទាំងឡាយដែលលោកអ្នកត្រូវការដើម្បីជាឡើងវិញពីការរងរបួសរបស់លោកអ្នក ហើយវិលត្រឡប់ទៅធ្វើការវិញដោយសុវត្ថិភាព បានឆាប់តាមលទ្ធភាពអាចធ្វើទៅបាន។ គេក៏នឹងផ្តល់ជូនការផ្តត់ផ្តង់ដែលលឿន ហើយផ្ទាល់ខ្លួនសម្រាប់លោកអ្នក និងនិយោជករបស់លោកអ្នកផងដែរ ដើម្បីសម្របសម្រួលការផ្តត់ផ្តង់ និងសេវានានាដែលលោកអ្នកត្រូវការដើម្បីជាឡើងវិញពីរបួសរបស់លោកអ្នក ហើយវិលត្រឡប់ទៅធ្វើការវិញបានឆាប់ តាមលទ្ធភាពអាចធ្វើទៅបាន។

គេក៏នឹងជួយលោកអ្នក និងនិយោជករបស់លោកអ្នកផងដែរដើម្បីបង្កើត និងអនុវត្តគម្រោងការវិលត្រឡប់ទៅធ្វើការវិញមួយ ប្រសិនបើវាទំនងថាលោកអ្នកនឹងពុំអាចចូលធ្វើការវិញច្រើនជាងបួនសប្តាហ៍។



ReturntoWorkSA
Return to work.
Return to life.

## វេជ្ជបណ្ឌិត

វេជ្ជបណ្ឌិតរបស់លោកអ្នកវាយតម្លៃរបួសរបស់លោកអ្នក ហើយធ្វើការសម្រេចជាមួយលោកអ្នកអំពីប្រភេទនៃការព្យាបាលមួយណាដែលលោកអ្នកតម្រូវ។ វេជ្ជបណ្ឌិតនឹងជួយលោកអ្នកដើម្បីកំណត់គោលដៅការព្យាបាល ហើយរួមចំណែកដល់ការបង្កើតគម្រោងការជាឡើងវិញ និងការវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នក ។

វាជាការសំខាន់ដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងការព្យាបាលរបស់លោកអ្នក ដើម្បីធ្វើឲ្យប្រាកដថាលោកអ្នកទទួលបានលទ្ធផលដ៏ល្អបំផុតដែលអាចធ្វើបាន។ ដោយការផ្តល់នូវមតិពីដំណើរការព្យាបាលរបស់លោកអ្នក លោកអ្នកក៏អាចជួយវេជ្ជបណ្ឌិតរបស់លោកអ្នកដែរ ដើម្បីរៀបចំគម្រោងការព្យាបាលដ៏សមរម្យបំផុត សម្រាប់កាលៈទេសៈជាក់លាក់របស់លោកអ្នក។

## ស្ថាប័នផ្តល់សេវាសុខភាពដែលរួមសម្ព័ន្ធ

វេជ្ជបណ្ឌិតរបស់លោកអ្នកអាចបញ្ជូនលោកអ្នកទៅស្ថាប័នផ្តល់សេវាសុខភាពដែលរួមសម្ព័ន្ធមួយ ដែលគេនឹងផ្តល់ជូនការព្យាបាល ដំបូន្មាន និងការផ្គត់ផ្គង់ដើម្បីជួយលោកអ្នកគ្រប់គ្រងរបួសរបស់លោកអ្នកដោយឯករាជ្យ និងវិលត្រឡប់ទៅធ្វើការវិញ ហើយប្រកបជីវិតរស់នៅរបស់លោកអ្នកឡើងវិញ។

## ស្ថាប័នផ្តល់សេវាត្រឡប់ទៅធ្វើការវិញ

អ្នកគ្រប់គ្រងករណីរបស់លោកអ្នក អាចទាក់ទិនជាមួយស្ថាប័នផ្តល់សេវាត្រឡប់ទៅធ្វើការវិញ ដើម្បីជួយលោកអ្នកជាមួយនឹងការដាក់ឲ្យមានការងារធ្វើការហ្វឹកហ្វឺន ឬអ្នកឯកទេសឯទៀតដូចជាគ្រូពេទ្យព្យាបាលធ្វើសកម្មភាពផ្សេងៗ ឬគ្រូពេទ្យព្យាបាល ដោយកាយវប្បកម្មក្នុងគោលបំណងត្រៀមខ្លួនលោកអ្នកជាស្រេចដើម្បីវិលត្រឡប់ទៅធ្វើការវិញ។

## អ្នកសម្របសម្រួលដើម្បីវិលត្រឡប់ទៅធ្វើការវិញ

ប្រសិនបើនិយោជករបស់លោកអ្នកមាននិយោជិត៣០នាក់ ឬច្រើនជាង  គេត្រូវរៀបចំឲ្យមានអ្នកសម្របសម្រួលដើម្បីវិលត្រឡប់ទៅធ្វើការវិញមួយរូបដែលបានទទួលការហ្វឹកហ្វឺន ដើម្បីជួយផ្គត់ផ្គង់លោកអ្នកបានជាឡើងវិញ ហើយវិលត្រឡប់ទៅធ្វើការវិញ។ អ្នកសម្របសម្រួលដើម្បីវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នកអាចៈ

- ជួយលោកអ្នកដើម្បីបំពេញហ្វ័មទាមទារ  និងក្រដាសស្នាមទាំងឡាយទៀត
- ជួបជាមួយលោកអ្នក និងអ្នកគ្រប់គ្រងករណីរបស់លោកអ្នក
- ជួយលោកអ្នកដើម្បីរក្សានៅកន្លែងការងារ ឬវិលត្រឡប់ទៅធ្វើការវិញ
- រក្សាការទាក់ទងជាមួយលោកអ្នក ភ្នាក់ងារទាមទារ និងស្ថាប័នផ្តល់សេវាផ្នែកពេទ្យឯទៀត
- ចាត់វិធានការដើម្បីបង្ការការរងទុក្ខពីការរងរបួសរបស់លោកអ្នក ដើម្បីកុំឲ្យកើតមានការរងរបួសឡើងវិញ ឬកើតមានការរងរបួសបន្ថែមទៀត
- ជួយជាមួយនឹងការរៀបចំគម្រោងការវិលត្រឡប់ទៅធ្វើការវិញ
- ពិនិត្យមើលដំណើរជឿនលឿននៃសមត្ថភាព និងការវិលត្រឡប់ទៅធ្វើការវិញរបស់លោកអ្នក។

ប្រសិនបើកន្លែងធ្វើការរបស់លោកអ្នកពុំមានអ្នកសម្របសម្រួលទេ សូមនិយាយទៅកាន់អ្នកគ្រប់គ្រងករណីរបស់លោកអ្នក ដើម្បីឲ្យបានដឹងថាតើគេអាចធ្វើអ្វីបានខ្លះដើម្បីជួយលោកអ្នក។

## ព័ត៌មានបន្ថែម

ដើម្បីទាក់ទងជាមួយ ReturnToWorkSA ក្នុងភាសាក្រៅពីភាសាអង់គ្លេស សូមទូរស័ព្ទមកមជ្ឈមណ្ឌលបកប្រែភាសា និយាយ និងភាសាសរសេរ លេខ 1800 280 203 រួចស្នើសុំឲ្យគេទាក់ទងមកយើងខ្ញុំលេខ 13 18 55។ សេវាបកប្រែភាសានេះមានផ្តល់ជូនដោយពុំគិតថ្លៃពីលោកអ្នកឡើយ។



ReturntoWorkSA
Return to *work.*
Return to *life.*